**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តស្ទឹងត្រែង**

សំណុំរឿងព្រហ្មទណ្ឌលេខ១៦០
ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៧
សាលក្រមលេខ: ០៧៣ (គ)
ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២១

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តស្ទឹងត្រែង**

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តស្ទឹងត្រែង នៅថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ វេលាម៉ោង ០៩:០០នាទីព្រឹក និងធ្វើការប្រកាសសាលក្រមនៅថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២១ វេលាម៉ោង ០៨ :០០នាទីព្រឹក ដែលមានសមាសភាពដូចតទៅ ៖

**ចៅក្រមជំនុំជម្រះ**

-លោក [redacted] ចៅក្រមសាលាដំបូងខេត្តស្ទឹងត្រែង

**តំណាងអយ្យការ**

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្ត

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តស្ទឹងត្រែង

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ១៦០ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៧ ដែលមានជនជាប់ចោទ៖

១-នាម-គោត្តនាម[redacted] ភេទប្រុស អាយុ៣៥ឆ្នាំ ជនជាតិខ្មែរ មុខរបរធ្វើស្រែចម្ការ ទីកន្លែងកំណើត និងទីលំបច្ចុប្បន្នភូមិក្បាលរមាស ឃុំក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែង ឪពុកឈ្មោ[redacted] (រស់) ម្តាយឈ្មោះ[redacted] (រស់) ប្រពន្ធឈ្មោះ[redacted] មានកូនចំនួន០៣នាក់ ជានីតិជន ទោសពីមុន គ្មាន ។

២-នាម-គោត្តនាម[redacted] ភេទស្រី អាយុ៤៨ឆ្នាំ ជនជាតិខ្មែរ មុខរបរធ្វើស្រែចម្ការ ទីកន្លែងកំណើត និងទីលំបច្ចុប្បន្នភូមិក្បាលរមាស ឃុំក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែង ឪពុកឈ្មោះ[redacted] (រស់) ម្តាយឈ្មោះ[redacted] (រស់) ប្តីឈ្មោះ[redacted] មានកូនចំនួន០៤នាក់ ជានីតិជន ទោសពីមុន គ្មាន ។

៣-នាម-គោត្តនាម[redacted] ភេទស្រី អាយុ២៩ឆ្នាំ ជនជាតិខ្មែរ មុខរបរធ្វើស្រែចម្ការ ទីកន្លែងកំណើត និងទីលំបច្ចុប្បន្នភូមិក្បាលរមាស ឃុំក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែង ឪពុកឈ្មោះ[redacted] (រស់) ម្តាយឈ្មោ[redacted] (រស់) នៅលីវ ជានីតិជន ទោសពីមុន គ្មាន ។

ត្រូវចោទពីបទៈ **ញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ និងប្រឆាំងអ្នករាជការសាធារណៈ** ប្រព្រឹត្តនៅចំណុចទំនប់វារីអគ្គិសនី សេសានក្រោមពីរ ស្ថិតក្នុងភូមិក្បាលរមាស ឃុំក្បាលរមាស ស្រុកសេសាន [illegible]ទី២៣ ខែកក្កដា ឆ្នាំ២០១៧ **តាមបញ្ញត្តិមាត្រា៤៩៥ និងមាត្រា៥០៣ នៃក្រម**

ថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃទី ១៥ ខែ មិនា ឆ្នាំ ២០២១
ក្រឡាបញ្ជី
[redacted]

ព្រហ្មទណ្ឌ។

-លោក[redacted] ជាមេធាវីការពារក្តីឲ្យជនជាប់ចោទ។

-លោកស្រី[redacted] ជាមេធាវីការពារក្តីឲ្យជនជាប់ចោទ។

-លោក [redacted] ជាមេធាវីការពារក្តីឲ្យជនជាប់ចោទ។

**១.<u>អង្គហេតុមានដូចតទៅ</u>**

កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៧ នៅចំណុចទំនប់វារីអគ្គិសនីសេសានក្រោមពីរ ស្ថិតក្នុងភូមិក្បាលរមាស ឃុំក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែង ឈ្មោះ[redacted]ង ឈ្មោះ[redacted] បានធ្វើសកម្មភាពញុះញង់ និងរារាំងមិនឲ្យអាជ្ញាធរមូលដ្ឋានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ និងប្រជាពលរដ្ឋដែលមាននិន្នាការផ្សេងពីពួកគេ ចូលទៅក្នុងភូមិក្បាលរមាសចាស់ដើម្បីបំពេញភារៈកិច្ចទេ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ១១៨៩ អ.យ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងខេត្តស្ទឹងត្រែង។

-បានឃើញ ដីកាដំណោះស្រាយបញ្ជូនសំនុំរឿងទៅជំនុំជម្រះលេខៈ៣៧៤ ព.ស ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តស្ទឹងត្រែង។

**២.<u>នាពេលសវនាការ</u>**

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ[redacted] បានឆ្លើយនាពេលសវនាការថាៈ កាលពីដំបូងកាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៧ មានកម្មវិធីសែនព្រេនតាមប្រណៃណីរបស់ជនជាត់ដើមភាគតិចដើម្បីសុំសេចក្តីសុខ នៅក្នុងការសែនភូមិតាមប្រពៃណីជនជាតិដើមភាគតិចនេះ បានធ្វើឡើងនៅផ្ទះមេកន្ទ្រាញឈ្មោះ លោកតា[redacted] មានចាស់ទុំផ្សេងៗទៀត និងមានប្រជាជនចូលរួមព្រមទាំងខ្លួនបានចូលរួមក្នុងការសែនព្រេននោះផងដែរ ខ្លួនមិនបានរារាំងទៅដល់សមត្ថកិច្ចឡើយ។ ខ្លួនមិនព្រមផ្លាស់ចេញពីទីលំនៅកន្លែងចាស់ ដើម្បីទៅរស់នៅទីកន្លែងថ្មីដែលគេបានដោះដូរឲ្យឡើយ ទោះបីជាមានទឹកឡើងមកលិចទីកន្លែងដែលខ្លួនរស់នៅក៏ខ្លួនមិនព្រមចាក់ចេញដែរ។

-ក្រឡាបញ្ជីអានចម្លើយរបស់ជនជាប់ចោទឈ្មោះ[redacted] បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរៈ ពេលព្រឹកថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៧ ខ្លួននៅផ្ទះកំពុងដាំបាយធ្វើម្ហូបនិងនាំកូនៗហូបជុំគ្នាសម្រាប់គ្រួសារពេលហូបបាយរួច ស្រាប់តែប្អូនរបស់ខ្លួនឈ្មោះ[redacted] បានមកដល់ផ្ទះខ្លួនថា បងបងទៅយកម៉ូតូនៅផ្លូវផង ព្រោះខ្លួនទុកចោលនៅផ្លូវចូល សូមទៅមើលផង មិនដឹងថានៅ ឬមិននៅទេ។ ខ្លួនបានសួរអ្នកភូមិជិតផ្លូវនោះគាត់ប្រាប់ថា គេលើកដាក់ឡានបាត់គេយកហើយអូន មិនបាច់រកទេ ។ ខ្លួនឃើញមនុស្សច្រើននៅទីនោះ ប្រហែលម៉ោង១១ថ្ងៃត្រង់មានអ្នកភូមិច្រើនមកជួយរកម៉ូតូនៅមាត់ផ្លូវឃើញប៉េអឹម ប៉ូលីសមានកាំភ្លើង ពេលនោះអ្នកភូមិបានស្រែកទាមទារនៅមុខប៉េអឹមថាឲ្យម៉ូតូអ្នកភូមិវិញ បើមិនឲ្យទេ ប្តឹងទៅសម្តេច ហ៊ុន សែន ថាចៅហ្វាយស្រុកលួចម៉ូតូអ្នកភូមិ។ ខ្លួនក៏ទាមទារយកម៉ូតូខ្លួនវិញដែរ ព្រោះម៉ូតូនោះ[redacted]ង ប្រើឲ្យទិញបារី១សុង សម្រាប់យកទៅសែនថ្ងៃស្អែក។ ពេលនោះឮអ្នកភូមិជាប់ផ្លូវនិយាយថាមានឡានត្រូវគេឃាត់ មិនដឹងថាឡានមកពីណាទេ។ ខ្លួនសួរឡានចូលមកភូមិថា មកពីណាពួកគាត់ថាមកចូលរួមសែន ព្រោះមានបងប្អូននៅភូមិនោះ ហើយសែនពេលទឹកលិចយ៉ាងម៉េច ហើយពួកគាត់ក៏ប្រាប់ថា មានឡានផ្សេងទៀតថាគេឃាត់យកទៅខេត្តហើយ។ ខ្លួនមិនដឹងទេ គឺតែមករកម៉ូតូខ្លួន

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

[illegible] ៥ល្ងាចថ្ងៃដដែល ទើបខ្លួនបានត្រឡប់មកផ្ទះវិញជាមួយអ្នកភូមិទាំងអស់គ្នា

ថ្ងៃទី ០៩ ខែ [illegible] ឆ្នាំ ២០២១



**ក្រឡាបញ្ជី**

[redacted]

(៣)

ប្រហែល ៥០ ឬ ៦០ នាក់។ ខ្លួនទៅទីនោះមិនបានដឹងរឿងអីទេ តែទៅទីនោះដើម្បីយកម៉ូតូប៉ុណ្ណោះ។ នៅថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ ២០១៧ ពេលព្រឹកខ្លួនក៏បានចូលរួមសែនភូមិតាមប្រពៃណី នៅផ្ទះមេកន្រ្ទាញ ឈ្មោះ លោកតា[redacted]។ ខ្លួនមិនបានធ្វើសកម្មភាពខុសច្បាប់ ឬទៅញុះញ៉ង់ ឬ ធ្វើសកម្មភាពប្រឆាំង ដូចការចោទប្រកាន់នោះឡើយ ចំពោះម៉ូតូនោះ Honda dream C 125 ពណ៌ខ្មៅ ពាក់ស្លាក់លេខស្នឹងក្រែង ១A-៤៥៥៨ ហើយបច្ចុប្បន្នម៉ូតូនោះកំពុងរក្សាទុកនៅអធិការដ្ឋាននគរបាលស្រុកសេសាន។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ[redacted]បានឆ្លើយនាពលសវនាការថា៖ កាលពីថ្ងៃទី ២៣ ខែកញ្ញ ឆ្នាំ២០១៧ មានកម្មវិធីសែនព្រេននៅក្នុងភូមិក្បាលរមាសដែលមានការរៀបចំដោយចាស់ទុំនៅក្នុងភូមិ ពាក់ព័ន្ធនៅក្នុងការរៀបចំពីធីសែនព្រេននេះពួកគាត់មានខ្វះបារី បានឲ្យខ្លួនជាអ្នកទៅទិញបារី ខ្លួនក៏បានខ្ចីម៉ូតូបងស្រីរបស់ខ្លួនដើម្បីធ្វើដំណើរទៅទិញបារី នៅផ្លូវប្រេកចូលភូមិក្បាលរមាស ខ្លួនបានទិញបារីចំនួន១សុងដាក់នៅកែបម៉ូតូ ក៏បានត្រលប់មកវិញត្រូវបាន គេចាប់យកម៉ូតូរបស់ខ្លួនដែលខ្លួនបានខ្ចីបងស្រីរបស់ខ្លួនទៅទិញបារី ខ្លួនបានសុំម៉ូតូវិញប៉ុន្តែគេមិនឲ្យ បន្ទាប់មកខ្លួនក៏បានដើរត្រលប់មកភូមិវិញ ខ្លួនក៏បានប្រាប់អ្នកភូមិថាគេបានចាប់យកម៉ូតូខ្លួនបាត់ហើយបន្ទាប់មកអ្នកភូមិបានទៅជួយរកម៉ូតូ ចំណែកខ្លួនក៏បាននៅមើលចាស់ទុំរៀបចំពិធីសែនព្រេននៅក្នុងភូមិ។ ខ្លួនមានដីស្រែចំការ ប៉ុន្តែជាដីរបស់ឪពុកម្តាយរបស់ខ្លួនទេ មានចំនួនបួន ទៅប្រាំកន្លែង ហើយដីនេះពុំមានប័ណ្ណកម្មសិទ្ធទេ។ ចំពោះការដែលឲ្យពួកខ្លួនចាកចេញពីទីកន្លែងចាស់ដែលខ្លួនបានរស់នៅ គឺពួកខ្លួនមានការសោកស្តាយចំពោះការចាកចេញ ការបាត់បង់ផ្ទះសំបែង ដីស្រែចំការ ហើយពួកខ្លួនក៏មានដីមួយចំណែកទៀតដែលអាចបង្ករបង្កើនផលបាន ទើបមិនអាចចាកចេញពីទីកន្លែងនេះបានឡើយ ។

-ក្រឡាបញ្ជីអានចម្លើយរបស់ជនជាប់ចោទឈ្មោះ[redacted] នៅដំណាក់កាលចៅក្រមស៊ើបសួរថា៖នៅថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០១៧ ព្រឹក ខ្លួននៅជាមួយចាស់ទុំមើលគាត់រៀបចំទីកន្លែងសែនដូចជារានត្បាញរៀប ចំស្រា ខ្លួនមើលចាស់ទុំ ដើម្បីរៀនសូត្រពីចាស់ទុំក្នុងការរៀបចំពិធី មានមាន់ ជ្រូក១ ស្រាពីរពាង មានទឹកក្រូច តែខ្វះបារី ។ ពេលនោះ ចាស់ទុំថា អាអូន ទៅទិញបារីមករៀបសែនផង និងបារីជក់ផង ។ នៅក្នុងភូមិនោះ មិនមានបារីលក់ទេ ព្រោះអ្នកលក់ចេញទៅភូមិថ្មីអស់ហើយ ខ្លួនអត់មានម៉ូតូខ្លួនឯងទេក៏បានខ្ចីម៉ូតូបងថ្លៃខ្លួនឈ្មោះ[redacted]ដើម្បីជិះទៅទិញបារីនៅមាត់ផ្លូវចេញពីភូមិ ពេលទៅដល់កន្លែងទិញបារី ខ្លួនបានទិញបារី០១សុង ហើយក៏ជិះម៉ូតូត្រឡប់មកផ្ទះវិញ ។ នៅកន្លែងទិញបារីខ្លួនមិនឃើញមានប៉ូលីសឬប៉េអិមទេ ហើយក៏មិនឃើញចៅហ្វាយស្រុកនោះដែរ ។ ពេលខ្លួនជិះដល់ផ្លូវបត់ចូលភូមិវិញចម្ងាយប្រហែល ៥០០ម៉ែត្រពីកន្លែងទិញបារី ខ្លួនក៏ឃើញឡានព៌ណស ធំជាងឡានសាំយ៉ុង និងឡានមួយទៀតព៌ណខ្មៅចតនៅទីនោះខ្លួនក៏បានជិះហួសពីឡានប្រហែល១០០ម៉ែត្រក៏មិនបានសួរគេដែរ មិនស្គាល់គេទេ ខ្លួនមិនអស់ចិត្តក៏បានចតម៉ូតូហើយដើរទៅសួរអភិបាលស្រុកដែល ឈរនៅទីនោះ ព្រោះខ្លួនស្គាល់គាត់ថា ៖ បងឡាននឹងម៉េចបានចតហ្នឹង? ខ្លួនក៏បន្តសួរអភិបាលស្រុក ហើយគាត់នៅតែមិនបានឆ្លើយ។ បន្ទាប់មកខ្លួនក៏ដើរមករកម៉ូតូខ្លួនវិញបន្ទាប់មករៀបនឹងបញ្ឆេះម៉ូតូជិះចូលមកភូមិវិញ រំពេចនោះ ក៏ស្រាប់តែអភិបាលស្រុកមកពីក្រោយខ្នងខ្លួន និងគាត់ក៏បានដកយកសោរម៉ូតូខ្លួន។ ខ្លួនសុំសោរពីគាត់វិញហើយគាត់មិនឲ្យ ហើយថែមទាំងស្ទុះមកចាប់ក្រៀកកខ្លួនជាប់ រួចអូសខ្លួនសំដៅទៅចូលឡានគាត់ព៌ណខ្មៅចតនៅជិតទីនោះ។ ខ្លួនមិនបានរើខ្លាំងទេព្រោះឆ្ងល់ថា ម៉េចបានគាត់ក្រៀកក ចាប់អូសខ្លួនមិនដឹងរឿងអ្វីសោះខ្លួនភ័យពេក តែជិតដល់ទ្វារឡានគាត់ ទើបខ្លួនខំប្រឹងយកដៃគាត់ចេញពីស្មានិងក ដែរដោយទុកម៉ូតូចោលនៅទីនោះ និងដើរមកផ្ទះនិងប្រាប់បង បាង ថាខ្លួនទុក

បានចំលងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃទី ០៩ ខែ មិនា ឆ្នាំ ២០១៨

ក្រឡាបញ្ជី

[redacted]

ម៉ូតូនៅផ្លូវ ចៅហ្វាយស្រុកគេដកសោរ និងអត់ឲ្យសោរខ្លួនវិញទេ ហើយរកចាប់គ្រៀកកខ្លួនទៀត អត់ដឹងចាប់ រឿងអី ។ ពេលទៅដល់ជួបចាស់ទុំ ក៏ពួកគាត់សួរថាម៉េចបានគេចាប់យកម៉ូតូ? ខ្លួនក៏បាននិយាយហេតុការណ៍ដូចខាងលើប្រាប់ចាស់ទុំដែរ ខ្លួនបាននៅជាមួយចាស់ទុំ សែនព្រេន និងនៅផ្ទះជាធម្មតា ។ ខ្លួនមិនបានប្រព្រឹត្តសកម្មភាព ឬទៅញុះញង់អ្នកភូមិឲ្យទៅធ្វើសកម្មភាពប្រឆាំងអ្នករាជការសាធារណៈដូចការចោទប្រកាន់ នោះឡើយ សូមតុលាការមេត្តាឈប់ចោទប្រកាន់ខ្លួនទៀតទៅ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយនាពលសវនាការថា៖ នៅក្នុងស្ថានភាពនេះគឺខ្លួនបាននៅផ្ទះបានរៀបចំបាយឲ្យប្អូនៗហូប បន្ទាប់មកមានក្មេងៗនៅក្នុងភូមិមកប្រាប់ខ្លួនថាពូរបស់ខ្លួនត្រូវបានគេយកម៉ូតូទៅបាត់ហើយ ពេលនោះខ្លួនបានចេញពីផ្ទះទៅពេលទៅដល់មានសួរសមត្ថកិច្ច ក៏សមត្ថកិច្ចមិនបានដឹងអំពីការបាត់ម៉ូតូនោះដែរ។ ប្រជាជនដែលមិនព្រមចាកចេញមានចំនួនរហូតដល់២០០ជាងនាក់ ពួកខ្លួនក៏មិនបានរារាំងចំពោះសមត្ថកិច្ចឡើយ គឺពួកខ្លួនស្ម័គ្រចិត្តរស់នៅដោយខ្លួនឯងផ្ទាល់។ នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៧ មានមនុស្សប្រហែលជា១០០ជាងនាក់បានចូលរួមក្នុងពិធីសែនព្រេន។

-ក្រឡាបញ្ជីអានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] នៅដំណាក់កាលចៅក្រមស៊ើបសួរថា៖ ប្រហែលម៉ោង ១០ ព្រឹក នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៧ ខ្លួននៅផ្ទះរបស់ខ្លួននៅភូមិក្បាលរមាសចាស់កំពុងហូបបាយជាមួយយាយនិងប្អូនៗ ពេលនោះមានអ្នកភូមិបានមកដល់ផ្ទះខ្លួន ហើយគាត់បានប្រាប់ថាមានគេឃាត់ម៉ូតូដែលជាកម្មសិទ្ធិអ្នកភូមិយើងនៅផ្លូវចូលភូមិហើយខ្លួន និងអ្នកភូមិប្រហែល៥នាក់បានឡើងជិះគោយន្ត១និងបានទៅដល់កន្លែងផ្លូវចូលភូមិស្រាប់តែខ្លួនឃើញមានមនុស្សច្រើន ព្រោងព្រាត មានអាជ្ញាធរ ប៉េអិម មានអាវុធក្នុងដៃនៅទីនោះដែរ ។ខ្លួនឈរមើលទីនោះ ក៏ឮមនុស្សកន្លែងនោះបាននិយាយថាអភិបាលស្រុកលួចម៉ូតូប្រជាជន ខ្លួនក៏គិតថា ម៉ូតូនៅជិតនឹង ក៏ប៉ុន្តែខ្លួនមិនឃើញម៉ូតូទេ ខ្លួនបានសួរពូប៉េអឹមម្នាក់ថា មានឃើញម៉ូតូអ្នកភូមិខ្លួនឬអត់។ តែគាត់ឆ្លើយថាមិនដឹងទេ សួរខ្ញុំធ្វើអី។ ប្រហែលពេលនោះឃើញមនុស្សច្រើនដែលនៅទីនោះដើម្បីសុំអង្វរយកម៉ូតូមកវិញក៏ប៉ុន្តែមិនឆ្លើយតបទេ។ ប្រហែលម៉ោង៥ រសៀលថ្ងៃដ៏ដែលនោះ នៅតែអត់មានឲ្យម៉ូតូវិញទេ ខ្លួនក៏ជិះគោយន្តជាមួយអ្នកភូមិត្រឡប់មកផ្ទះវិញនៅថ្ងៃដដែលនោះ។ ពេលទៅដល់ផ្ទះខ្លួនក៏មិនដឹងថា ម៉ូតូទុកនៅឯណា អ្នកណាយកក៏មិនបានដឹងដែរ តែឮ អ្នកភូមិថា អភិបាលស្រុកសេសានអ្នកយកម៉ូតូនោះទៅ។ ហើយល្ងាចប្រហែលម៉ោង ៥ ឬ ៦ ដដែលនោះ ខ្លួនក៏បានឮប៉ូលីសនៅផ្លូវចូលភូមិនិយាយថា មានឡានបងប្អូនពីខេត្តផ្សេងត្រូវបានឃាត់ និងសួរនាំនៅខេត្ត ហើយត្រូវបានឲ្យទៅផ្ទះវិញ។ លុះព្រឹកឡើង ចាស់ៗសុំឲ្យចាន់នីនៅភូមិ ជាអ្នកអាន ពាក្យរបស់ចាស់ទុំ និងអ្នកភូមិ តែចាន់នីអានមិនល្អ ចាស់ទុំក៏បានសុំនាងខ្ញុំឲ្យថ្លែងក្នុងពិធីសែនភូមិតាមប្រពៃណី។នាងខ្ញុំមិនបានធ្វើសកម្មភាពឬអំពើណាខុសច្បាប់ឬញុះញ៉ង់ឬ ប្រឆាំងអ្នករាជការសាធារណៈដូចការចោទ ប្រកាន់ខ្លួននោះឡើយហេតុនេះសូមតុលាការមេត្តាឈប់ចោទប្រកាន់ខ្លួនទៀតទៅ។

-តាមចម្លើយរបស់របស់សាក្សីឈ្មោះ [redacted] បានឆ្លើយនាពលសវនាការថា៖ កាលពីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៧ នៅចំណុចវារីអគ្គិសនីសេសានក្រោមពីរ ស្ថិតនៅភូមិក្បាលរមាស ឃុំក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែង ខ្លួនមិនបានដឹងរឿងអីទេ ព្រោះខ្លួនបានដូរចេញទៅរស់នៅភូមិក្បាលរមាសថ្មី តាំងពីចុងឆ្នាំ២០១៥ ដើមឆ្នាំ២០១៦ ខ្លួនគ្រាន់តែឮអ្នកភូមិក្បាលរមាសថ្មី និយាយថាសមត្ថកិច្ចកងរាជអាវុធ ចុះហាមឃាត់ក្រុមរបស់ឈ្មោះ [redacted] ឈ្មោះ [redacted] និងឈ្មោះ [redacted] ដែលបាន[illegible]កម្លាំងរាជអាវុធហត្ថ ចំពោះការដោះដូរពីភូមិក្បាលរមាសចាស់ ទៅរស់នៅភូមិ

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃទី ០៩ ខែ [illegible] ឆ្នាំ ២០២១
ក្រឡាបញ្ជី
[redacted]

ក្បាលរមាសថ្មី ខ្លួនទទួលបានសំណាងដី២០ម៉ែត្រ បណ្តោយ៥០ម៉ែត្រ លុយធ្វើផ្ទះចំនួន៦,០០០$ ដីស្រែចម្ការចំនួន០៥ហិចតា ប្រាក់កម្លាំងពលកម្ម និងប្រាក់ខាងវារីអគ្គិសនីគាំទ្រចំនួន៣,១០០$ មានធុងទឹកចំនួន០១ ចម្រុះ២,០០០លីត្រ ស្រះមួយទំហំ០៥ម៉ែត្រគុណនឹង១៦ម៉ែត្រ។

-តាមចម្លើយរបស់សាក្សីជាសមត្ថកិច្ចឈ្មោះ[redacted]បានឆ្លើយនាពេលសវនាការថា៖ កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៧ បានដំណើការបើកការស៊ើបអង្កេតបឋម ពីបទរាំងប្រឆាំងអ្នករាជការសាធារណៈ ដែលប្រព្រឹត្តឡើងភូមិក្បាលរមាស ឃុំក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែង ដែលបង្ករឡើងដោយឈ្មោះ[redacted] ។ ដំណើការនីតិវិធីនៃការប្រមែប្រមូលភស្តុតាងនៅក្នុងរឿងនោះ ដោយដើមហេតុដំបូងបានកើតឡើងដោយមានរបាយការណ៍មួយរបស់អធិការនគរបាលស្រុកសេសានបានរាយការណ៍អំពីសកម្មភាពកាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៧ នៅលើភូមិសាស្ត្រនេះ ដោយពួកគាត់បានប្រមែប្រមូលសកម្មភាពពីគ្រប់ទីសទី ដែលជាជនជាតិដើមភាគតិច ដោយមូលហេតុយកលេសដាក់បញ្ហាទៅលើការជួបជុំគ្នាក្នុងការរៀបចំពិធីសែនព្រេន ដំណាមនៅក្នុងភូមិប្រពៃណីរបស់ជនជាតិដើមភាគតិច ដោយជនទាំងបីខាងលើបានបំផុសញុះញ៉ង់ប្រជាពលរដ្ឋតាមរយៈការយកទំនៀមទំលាប់ប្រពៃណី ជនជាតិព្នង មកធ្វើជាខែល ដោយរៀបចំពិធីសែនព្រេន ហើយ ធ្វើស្លាកសញ្ញា និង សរសេរខ្លឹមសារ ដាក់នៅគ្រប់ផ្លូវច្រកចូលភូមិថា បើជនណាមិនគោរពតាមតំណមនេះ ត្រូវពិន័យ ក្របី១ក្បាល ជ្រូក១០០គីឡូ លុយ១០០០$ និងស្រា០៧ពាង ម្យ៉ាងវិញទៀតជនទាំងបីនាក់ដែលមានឈ្មោះ[redacted] រាល់បញ្ហាទាំងឡាយគឺពួកគាត់តែងតែចេញមុខឈរ ជាតំណាងអោយមហាជន ជាអ្នកចេញមុខបញ្ចេញនៅទស្សនៈ ។ខណៈនោះមន្ត្រីនគរបាលយុត្តិធម៌ និងក្រុមការងារចុះទៅគឺមិនអាចចូលទៅក្នុងភូមិបាន ពុំមានឱកាសនៅក្នុងការចូលរួមពុំមានកិច្ចសហការ ជាមួយមន្ត្រីនគរបាលយុត្តិធម៌ សូម្បីតែខាងសមត្ថកិច្ចបានកោះហៅតាមនីតិវិធីក៏ពួកគាត់មិនបានចូលរួមតាមការស៊ើបអង្កេតបឋម រហូតដល់មានដីកាបង្គាប់ឲ្យចូលខ្លួន ។ ជាក់ស្តែងនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៧ ឈ្មោះ[redacted]បានប្រមូលគៀងគរជនជាតិដើមភាគតិចពីខេត្តរតនៈគីរី ខេត្តមណ្ឌលគីរី ព្រះវិហារ មកធ្វើពិធីសែនព្រេននៅក្នុងភូមិក្បាលរមាស ហើយឈ្មោះ[redacted] បានធ្វើសេចក្តីថ្លែងការណ៍ពីទីនោះ ដោយបានថតជាឃ្លីបវីដីអូរ ហើយបង្ហោះនៅក្នុង Acount Facebook ឈ្មោះ[redacted] ហើយប្រកាសពីតំណមភូមិរហូតដល់ខែតុលាឆ្នាំ២០១៧។ ហើយនៅក្នុងដំណាក់កាលនោះគឺជាដំណាក់កាលមួយដែលរដ្ឋបាលខេត្តស្ទឹងត្រែងក៏ដូចជារាជរដ្ឋាភិបាលបានចាប់ផ្តើមធ្វើការបិទទំបនប់ថាវីអគ្គីសនីសេសាន២ ដើម្បីដំណើកិច្ចការងារសាកល្បងវារីអគ្គិសនី ដែលតម្រូវឲ្យប្រជាពលរដ្ឋទាំងអស់ចាក់ចេញពីដំបន់នេះដែលត្រូវបានគេកំណត់ជាតំបន់ទំនប់បាតអាងវារីអគ្គីសនី ជាកន្លែងដែលបណ្តាលឲ្យគ្រោះថ្នាក់ដល់ប្រជាពលរដ្ឋដែលរស់នៅតំបន់នោះ ហើយដើមទងនៃសាច់រឿងដូចបានលោកមេឃុំ លោកអភិបាលរងស្រុក ដែលជាក្រុមការងារផ្ទាល់លោកបានចុះធ្វើការសម្របសម្រួលជាមួយ និងប្រជាពលរដ្ឋដែលមាននិន្នាការមិនព្រមទទួលយកសំណាង មិនព្រមទទួលយកការអភិវឌ្ឍន៍ របស់រាជរដ្ឋាភិបាលក៏ដូចជាអាជ្ញាធរខេត្ត ដែលលោកតែងតែជួបប្រទះ ទៅនឹងការរារាំង ជារឿយៗ ជាក់ស្តែងក្រុមការងាររដ្ឋបាលខេត្តជាច្រើនក្រុមបានបង្កើតការងារជាច្រើនក្រុមបានចុះជួប ជាច្រើនលើកច្រើនសារនៅភូមិក្បាលរមាសចាស់ ក៏ប៉ុន្តែសមាសភាពដែលដឹកនាំដោយឈ្មោះ[redacted] ជាពិសេស គឺតែងតែចេញមុខរាំងមិនទទួលយកការ[illegible]កសំណាងពីអាជ្ញាធររបស់រដ្ឋបាលសាលាខេត្ត ក៏ដូចជារាជរដ្ឋាភិបាល គឺទាញ

ចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃទី ០៨ ខែ[illegible] ឆ្នាំ២០២២
ក្រឡាបញ្ជី
[redacted]

យកតែពីហេតុផលដែលខ្លួនចង់បាន ដោយមិនគិតពីគោលការណ៍នៃការអភិវឌ្ឍន៍ ដោយនិយាយមិនព្រមស្តាប់គ្នា មិនព្រមទទួលយក។ រហូតឈានដល់បានទទួលដីកាបង្គាប់ឲ្យចូលខ្លួនរបស់ឈ្មោះ[redacted] ,ឈ្មោ[redacted] បន្ទាប់មកក្រុមការងារបានចុះអនុវត្តធ្វើការស្រាវជ្រាវជនទាំងបីនាក់ ប៉ុន្តែជនទាំងបីនាក់នេះបានគេចខ្លួនទៅរាជធានីភ្នំពេញ ដោយការងាររបស់យើងខ្ញុំបានបន្តបេសកកម្ម និងសហការដើម្បីអនុវត្តរហូតដល់ពួកគាត់ទាំងបីនាក់ បានត្រលប់មកវិញ ក្រុមការងារយើងខ្ញុំបានធ្វើរបាយការណ៍ស្តីពីលទ្ធផលការស្រាវជ្រាវ និងបានបញ្ជូនសំណុំរឿងនោះមកអយ្យការដើម្បីចាត់ការបន្ត។

-តាមចម្លើយរបស់របស់សាក្សីជាអភិបាលរងស្រុកសេសាន បានឆ្លើយនាពេលសវនាការថា៖ ក្រុមការងារបានចុះផ្សព្វផ្សាយនៅភូមិក្បាលរមាស ឃុំក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែង អំពីបញ្ហាដែលមានផលប៉ះពាល់ ក៏ដូចជាការផ្លាស់ប្តូរពីទីកន្លែងដែលរស់នៅចាស់ អោយទៅរស់នៅលើទីកន្លែងថ្មីដែលជាសំណងក្នុងការផ្លាស់ប្តូរ ប្រជាពលរដ្ឋមួយចំនួនព្រមទទួលយកសំណង និងព្រមផ្លាស់ប្តូរទីលំនៅទៅរស់នៅទីកន្លែងថ្មី ប៉ុន្តែប្រជាពលរដ្ឋមួយចំនួនទៀតមិនព្រមចាកចេញ និងទទួលយកសំណងជាដាច់ខាត ហើយថែមទាំងបង្កនូវការប្រឆាំងតវ៉ា ឃាត់រាំងគ្រឿងចក្រ មិនអោយដំណើរការ ដោយបាននាំគ្នារុំឈើ និងឫស្សីដើម្បីជ្រលក់ប្រេងទៅដុតគ្រឿងចក្រ ជាហេតុធ្វើឲ្យក្រុមការងារខាងគ្រឿងចក្រត្រូវបានផ្អាកដំណើរការដោយប្រមូលផ្តុំនៅមួយកន្លែង។

-តាមចម្លើយរបស់របស់សាក្សីឈ្មោ[redacted] បានឆ្លើយនាពលសវនាការថា៖ ឆ្នាំ២០១៤ ខាងអាជ្ញាធរភូមិ ឃុំ ស្រុក ក្រុង ខេត្ត និងក្រុមហ៊ុនវារីអគ្គិសនី បានទៅផ្សព្វផ្សាយដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងភូមិក្បាលរមាស ឃុំក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែងអំពីការបិទទំនប់វារីអគ្គិសនីសេសានក្រោមពីរ ដោយសារមានទឹកលិចនៅភូមិប្រជាពលរដ្ឋដែលរស់នៅភូមិក្បាលរមាសនោះ និងមានការដោះដូរនូវភូមិថ្មី ព្រមទាំងមានសំណងជូនប្រជាពលរដ្ឋវិញនូវដីប្រាំហិចតា ផ្ទះមួយខ្នង៨០ម ដីលំនៅដ្ឋាន ២០ម៉ែត្រគុណនឹង៥០ម៉ែត្រ សំណងដំណាំជុំវិញផ្ទះ ទ្រុងជ្រូក ទ្រុងមាន់ ក្រោលគោ និងរបងមានឈើថ្មបង្គន់ (អង្គរង្វាន់លើកទឹកចិត្តអ្នកដែលចេញទៅមុនគេចំនួន២០០$)សម្រាប់គ្រួសារចាស់។ ចំពោះប្រជាពលរដ្ឋដែលបំបែកគ្រួសារថ្មី ទទួលបានដី លំនៅដ្ឋានទំហំ២០ម៉ែត្រគុណនឹង៥០ម៉ែត្រ ដីកសិកម្មចំនួន ០២ហិចតា មានប្រជាពលរដ្ឋមួយចំនួនធំ (ជាង១០០គ្រួសារ ព្រមទាំងទទួលយកសំណង និងចាកចេញទៅរស់នៅលំនៅដ្ឋានថ្មី នៅសល់តែគ្រួសារមួយចំនួនតូច (៣០គ្រួសារ មិនព្រមទទួលយកសំណង និងមិនទៅរស់នៅលំនៅដ្ឋានថ្មី គឺមានគ្រួសារឈ្មោះ[redacted] ក្នុងការផ្សព្វផ្សាយជាច្រើនលើកច្រើនសារ រាល់ការចុះទៅផ្សព្វផ្សាយនោះគឺឈ្មោះ[redacted] និងឈ្មោះ[redacted] មានចូលរួម មានអត់ចូលរួម តែងតែជំទាស់រហូត និងបានដើរចេញទៅមិនព្រមនៅស្តាប់។ នៅពេលដែលក្រុមការងារយកគ្រឿងចក្រមកដាក់ដើម្បីរៀបចំធ្វើតែត្រូវបានប្រជាពលរដ្ឋនាំគ្នារាំង ដោយបានរុំឈើ និងឫស្សីដើម្បីជ្រលក់ប្រេងទៅដុតគ្រឿងចក្រ ជាហេតុធ្វើឲ្យក្រុមការងារខាងគ្រឿងចក្រត្រូវបានផ្អាកដំណើរការដោយប្រមូលផ្តុំនៅមួយកន្លែង។

-តាមចម្លើយរបស់របស់សាក្សីឈ្មោ[redacted] បានឆ្លើយនាពលសវនាការថា៖ នៅថ្ងៃដែលកើតហេតុនេះពួកខ្លួនទាំងអស់គ្នាគឺជាអ្នករៀបចំកម្មវិធីសែនព្រេនរបស់ជនជាតិដើមភាគតិច ព្រោះទឹកជិត[illegible]ស្មើៗ និងច្រាំងទឹកទំនប់ និងម្យ៉ាងវិញជាទំនៀមទំលាប់របស់ជនជាតិដើមភាគ

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃទី ០៩ ខែ [illegible] ឆ្នាំ [illegible]
ក្រឡាបញ្ជី
[redacted]

តិចការឈឺស្កាត់ គឺពួកគេតែងតែសែនព្រៃន និងព្យាបាលនៅពេទ្យផង។ ចំពោះការសែនព្រៃនគឺពួកខ្លួនបានរៀបចំពិធីសែនព្រៃនជារៀងរាល់ឆ្នាំ ដោយមានចាស់ទុំនៅក្នុងភូមិជាមេកន្ទ្រាញឈ្មោះ [redacted]។ ចំពោះរឿងនេះគឺមានអាជ្ញាធរបានជូនដំណឹងដល់ពួកខ្លួនទាំងអស់គ្នា ថាអោយទៅផ្លាស់ទីលំនៅទៅកន្លែងថ្មីដែលបានរៀបចំជំនួសទីកន្លែងចាស់ និងមានសំណងជូន ប៉ុន្តែពួកខ្លួនពុំព្រមចេញពីកន្លែងនេះឡើយ ព្រោះពួកខ្លួនបានកើតមកនៅទីកន្លែងនេះនិងរស់នៅតាំងពីយូរយាណាស់មកហើយ ហើយពួកខ្លួនទាំងអស់គ្នាបានប្តេជ្ញាចិត្តថាសុខចិត្តរស់នៅលើទីកន្លែងនេះផ្ទាល់ ទោះបីជាមានទឹកលិចយ៉ាងណាក៏ដោយក៏ពួកខ្លួនសុខចិត្តស្លាប់នៅទីកន្លែងនេះ ដោយមិនចាក់ចេញទេ។ ក្នុងការរៀបចំពិធីសែនព្រៃនគឺពួកខ្លួនពុំមានគំនិតថាប្រឆាំងនឹងសមត្ថកិច្ចទេគឺក្នុងគោលបំណងសុំតែសេចក្តីសុខតាមទំនៀមទំលាប់របស់ជនជាតិដើមភាគតិចតែប៉ុណ្ណោះ។

-តាមអំណានចម្លើយរបស់របស់សាក្សីឈ្មោះ [redacted] បានឆ្លើយថា៖ កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៧ ប្រហែលម៉ោងដប់មួយព្រឹក ខ្លួនបាននៅផ្ទះ ក៏បានឮគេនិយាយថា មានឡានបីគ្រឿងដែលបានជិះចូលមកភូមិក្បាលរមាស ឃុំក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែង ដែលមានឡានហុងឡានសាំងយ៉ុង និងឡានប្រភេទឡានក្រុងតូច ដែលបានជិះចេញមកពីខេត្តមណ្ឌលគីរី រតនគីរី និងស្ទឹងត្រែង ដែលមកធ្វើពិធីសែនលក្ខណៈប្រពៃណីដូនតា ជារៀងរាល់ឆ្នាំ របស់ជនជាតិដើមភាគតិច ពេលជិះមកដល់ផ្លូវបត់កែងចូលក្បាលរមាស ស្រែគរ ក៏ត្រូវសមត្ថកិច្ចចាប់ឃាត់រថយន្តមួយគ្រឿងជាឡានប្រភេទឡានក្រុងតូច ក៏បានបញ្ជូនទៅខេត្តស្ទឹងត្រែង អ្នកភូមិក៏បានតវ៉ាជាមួយសមត្ថកិច្ចឲ្យជួយរកដំណោះស្រាយ ដោះលែងឡានដែលសមត្ថកិច្ចបានចាប់ រួចហើយក៏មានការតវ៉ាខ្លាំងទើបសមត្ថកិច្ចដោះលែងឡាន និងមនុស្សដែលជិះក្នុងឡាននោះឲ្យត្រលប់មកវិញ អ្នកភូមិបានព្យាយាមតវ៉ាដើម្បីឲ្យមានដំណោះស្រាយ ដែលអ្នកភូមិរងប៉ះពាល់ពីការសាងសង់ទំនប់វារីអគ្គិសនី ដោយពួកគាត់បាននិយាយថា និងមិនចាកចេញពីកន្លែងរស់នៅសព្វថ្ងៃទេ សមត្ថកិច្ចបាននិយាយថាគាត់ពុំអាចដោះស្រាយបានទេ ពួកគាត់គ្រាន់តែជួយរក្សាសន្តិសុខដល់ប្រជាពលរដ្ឋមានបញ្ហា ដែលមានការចូលរួមប៉ូលីស ប៉េអឹម ដែលប្រចាំការនៅក្នុងតំបន់នោះ ហើយក៏មានការតវ៉ា មានមន្ត្រីកងរាជអាវុធហត្ថបានចូលរួមដោះស្រាយជាមួយប្រជាពលរដ្ឋ ដោយបាននិយាយថាធ្វើតាមបញ្ជាថ្នាក់លើទេ ដោយឲ្យមកជួយការពារប្រជាពលរដ្ឋនៅក្នុងតំបន់នេះ ប៉ុន្តែប្រជាពលរដ្ឋបាននិយាយថា ហេតុអ្វីបានជាមានការតាមដានគ្រប់សកម្មភាពរបស់ប្រជាពលរដ្ឋពីព្រោះពួកគាត់ពុំមែនជាអ្នកមានទោស ចុះហេតុអ្វីបានជាពេល ពលរដ្ឋធ្វើដំណើរមានសមត្ថកិច្ចជិះតាមពីក្រោយ តាមដានប្រជាពលរដ្ឋធ្វើអ្វី ហើយសមត្ថកិច្ចបាននិយាយថា ពលរដ្ឋអាចធ្វើដំណើរបានគ្រប់ពេលហើយសមត្ថកិច្ចធ្វើកិច្ចការរបស់សមត្ថកិច្ចទៅតាមតួនាទីហើយប្រជាពលរដ្ឋគាត់ថា សមត្ថកិច្ចមិនជួយដោះស្រាយ រួចហើយប្រជាពលរដ្ឋ ក៏បានតវ៉ាកាន់តែខ្លាំង ហើយសមត្ថកិច្ចនិយាយថាពិបាកនិយាយគ្នារួចបើកទ្វារឡានប្រុង និងទៅកន្លែងវិញ ប៉ុន្តែប្រជាពលរដ្ឋបានធ្វើការឡោមព័ទ្ធឡាន មិនឲ្យទៅណា ហើយប្រជាពលរដ្ឋខ្លះ បានចាក់ទ្វារឡាន ហើយក៏បាននិយាយ សម្របសម្រួលគ្នា ប្រហែលកន្លះម៉ោង ទើបប្រជាពលរដ្ឋអនុញ្ញាតឲ្យសមត្ថកិច្ចទៅរួច សមត្ថកិច្ចក៏បានយកកាំភ្លើងចេញពីក្រោយខ្នង បន្ទាប់មកប្រជាពលរដ្ឋពេលសមត្ថកិច្ចធ្វើបែបនេះ ក៏នាំគ្នាត្រលប់មកវិញ ហើយក៏និយាយថាសមត្ថកិច្ចមកគំរាមប្រជាពលរដ្ឋសមត្ថកិច្ចបាននិយាយថា ពួកគាត់ពុំមានសិទ្ធិប្រើប្រាស់អាវុធគាត់គ្រាន់តែយកមកការពារខ្លួន ជាមួយតួនាទីហើយប្រជាពលរដ្ឋក៏បានប្រមូលផ្តុំគ្នាម្តងទៀតរួចហើយក៏និយាយសម្របសម្រួល គ្នាសមត្ថកិច្ចបើក [illegible]បំបែកគ្នាប្រហែលម៉ោងបីរសៀលសមត្ថកិច្ច និងប្រជាពល រដ្ឋបានសម្រប

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១៧

ក្រឡាបញ្ជី

[redacted]

សម្រួលគ្នាមួយលោកមេប៉ុស្តិ៍ក្បាលរមាស លោកអភិបាលស្រុកសេសាន និងលោកមេភូមិមេភូមិ ក្បាលរមាសតែដោយសារសមត្ថកិច្ចចាប់គ្នាគាត់មួយឡាន ទើបគាត់តវ៉ាសុំឲ្យដោះលែងវិញពីព្រោះ ពួកគេបានមកសែនជូនតា ដើម្បីរើសភូមិទៅរស់នៅកន្លែងថ្មី និងជួយកាប់ឬស្សីអ្នកភូមិ ដើម្បីការពារគឺលិចលង់ដោយទឹកទន្លេ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថាៈ ឆ្លងកាត់តាមការពិភាក្សាដេញដោលក្នុងអង្គសវនាការ បានបញ្ជាក់ឲ្យឃើញថា កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៧ ពិតជាមានករណី ញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ និងប្រឆាំងអ្នករាជការសាធារណៈ ដែលប្រព្រឹត្តឡើងដោយឈ្មោះ[redacted] ពិតប្រាកដមែន។ ទោះបីជាមានការអះអាងពីសាក្សីដែលគាំទ្រពួកគាត់ទាំងបីនាក់នេះក៏ពុំមានភស្តុតាងណាមួយសម្រាប់ដោះបន្ទុកពួកគាត់បានឡើយ ដោយសារករណីទីមួយ មានការកោះហៅរបស់មន្ត្រីនគរបាលយុត្តិធម៌ ក៏ពួកគាត់មិនបានចូលមកបំភ្លឺដល់មន្ត្រីសមត្ថកិច្ចជំនាញទេដូច្នេះបង្ហាញឲ្យឃើញថាពួកគាត់បានដឹងពីកំហុសអំពីមូលហេតុ ដែលមន្ត្រីសមត្ថកិច្ចនគរបាលបានកោះហៅ ករណីទីពីរក្រោយពីបានប្រព្រឹត្តបទល្មើសរួចហើយគឺពួកគាត់ទាំងបីនាក់បានជម្លៀសខ្លួនទៅនៅទីកន្លែងផ្សេង នោះបានសបញ្ជាក់ឲ្យឃើញថាគាត់បានដឹងពីទង្វើរបស់ខ្លួនថាបើសិនជាពួកគាត់មកបំភ្លឺនោះគេនឹងចាប់ពួកគាត់ហើយដោយសារតែពួកគាត់បានធ្វើការ ញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ និងប្រឆាំងអ្នករាជការសាធារណៈនេះដូច្នេះតំណាងអយ្យការនៅរក្សាបទចោទប្រកាន់នៅដដែល និងស្នើសុំឲ្យក្រុមប្រឹក្សាជំនុំជម្រះដើម្បីពិនិត្យ និងសម្រេច។

-មេធាវីឈ្មោះ[redacted] ការពារក្តីឈ្មោះឲ្យជនជាប់ចោទឈ្មោះ[redacted] បានធ្វើសេចក្តីសន្និដ្ឋានថាៈ ខ្លួនជាមេធាវីការពារក្តីឲ្យជនជាប់ចោទ កូនក្តីរបស់ខ្លួន ពិតជាមិនបានប្រព្រឹត្តដូចការចោទប្រកាន់ឡើយគឺពុំមានអង្គហេតុច្បាស់លាស់ និងភស្តុតាងគ្រប់គ្រាន់ ទីមួយសម្រាប់ជនទាំងបីនាក់នេះគឺជាពលរដ្ឋ នៅក្នុងចំណោមប្រជាពលរដ្ឋ៣២គ្រួសារឬ៥២គ្រួសារគឺពួកគាត់មិនមែនជាអ្នកដែលរារាំង ជាអ្នកដែលប្រឆាំង ជាអ្នកដែលប្រព្រឹត្តដោយចេតនាឬប្រឆាំងដូចការចោទប្រកាន់នោះទេពីព្រោះរឿងទាំងអស់នេះ ពួកគាត់មានផ្ទះ មានដី មានទ្រព្យសម្បត្តិនៅទីនោះហើយការការពារទ្រព្យសម្បត្តិ ការតតាំង ដើម្បីអោយមានការដោះដូរជាមុន ការឯកភាពជាមុនគឺជាសិទ្ធិរបស់ពួកគាត់ដែលច្បាប់អនុញ្ញាត ទីពីរអត្តសញ្ញាណអ្នករាជការសាធារណៈនៅពេលដែលចុះទៅ ធ្វើអ្វីខ្លះហើយកូនក្តីរបស់ខ្លួនបានរារាំងអ្វីខ្លះ ពុំមានដាក់នៅក្នុងសំណុំរឿង ពុំមានអ្វីសម្រាប់ដាក់បន្ទុកទេ នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៧ ឆ្លងតាមការសន្និដ្ឋានរបស់តំណាងអយ្យការថាកូនក្តីរបស់ខ្លួនបានគេចវេសទៅភ្នំពេញ លើការសន្និដ្ឋានឃើញថាកូនក្តីមានការភ័យខ្លាច មិនមែនជាចេតនាប្រព្រឹត្តបទល្មើសហើយរត់គេចនោះទេ គឺដោយសារតែមានការភ័យខ្លាចដោយការចោទប្រកាន់សកម្មភាពដែលមិនព្រមចេញដែលការអះអាង និងបង្ហាញពីសាក្សី គឺជាដំណាក់កាលចរចារតំណាងរវាងរាជរដ្ឋាភិបាល តំណាងដោយក្រុមហ៊ុន អភិវឌ្ឍន៍ ជាមួយពួកគាត់ដែលជាម្ចាស់សិទ្ធិនៅលើដី ដំណើរការការចរចារនេះដូចច្នេះដំណើរការចរចារគឺត្រូវមានការតាំងទៅមកដើម្បីឲ្យមានការព្រមព្រៀង និងនៅថ្ងៃសែនព្រេនទៅតាមប្រពៃណី ចំពោះការប្រព្រឹត្ត ការប្រតិបត្តិត្រូវច្បាប់បានអនុញ្ញាត ដូចច្នេះក្នុងនាមខ្លួនជាមេធាវីការពារក្តីឲ្យជនជាប់ចោទស្នើសុំឲ្យកូនក្តីរបស់ខ្លួនរួចពីបទចោទប្រកាន់។

-មេធាវីឈ្មោះ[redacted] ការពារក្តីឈ្មោះឲ្យជនជាប់ចោទឈ្មោះ[redacted]បានធ្វើសេចក្តីសន្និដ្ឋានថាៈ យោងតាមមាត្រា៣៥ រដ្ឋធម្មនុញ្ញបានចែងថាប្រជា

ចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃទី ០៩ ខែ ០៧ ឆ្នាំ ២០២១
ក្រឡាបញ្ជី
[redacted]

ពលរដ្ឋតាំងពីរភេទមានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ទាក់ទងនិងការដាក់ស្លាកសញ្ញា ការរៀបចំពិធីសែនព្រេន គឺមិនមែនជាការញ៉ុះញ៉ង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ និងប្រឆាំងអ្នករាជការសាធារណៈ ដូចច្នេះក្នុងនាមខ្លួនជាមេធាវីការពារក្តីឲ្យជនជាប់ចោទ ស្នើសុំឲ្យកូនក្តីរបស់ខ្លួនរួចពីបទចោទប្រកាន់។

-មេធាវីឈ្មោះ [redacted] ការពារក្តីឈ្មោះឲ្យជនជាប់ចោទឈ្មោះ [redacted] និងឈ្មោះ [redacted] បានធ្វើសេចក្តីសន្និដ្ឋានថា៖ កូនក្តីរបស់ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ដោយឡែកនៅក្នុងសំណុំរឿងពុំមានភស្តុតាងណាសម្រាប់ដាក់បន្ទុកឆ្លើយបញ្ជាក់ឲ្យឃើញច្បាស់ថាកូនក្តីខ្លួនបានញ៉ុះញ៉ង់អោយនរណាក់ម្នាក់ទៅប្រព្រឹត្ត ឬទៅប្រឆាំងរារាំងទៅនឹងសមត្ថកិច្ចឡើយគឺសកម្មភាពរបស់ពួកគាត់ការបញ្ចេញមតិយោបល់គឺជាសិទ្ធិរបស់ពួកគាត់ នៅក្នុងការជួយគ្នាដើម្បីអោយមានដំណោះស្រាយមួយដែលអាចទទួលយកបាននៅក្នុងបញ្ហាដីធ្លីរបស់ពួកគាត់នេះ ក្នុងអង្គសវនាការមានសាក្សីជាប្រជាជនគាត់បានបញ្ជាក់យ៉ាងច្បាស់ថាគាត់សុខចិត្តរស់នៅលើរបស់ពួកគាត់ ទាំងអស់នេះបានសបញ្ជាក់ឲ្យឃើញថាគឺជាទឹកចិត្តផ្ទាល់ខ្លួនរបស់ពួកគាត់ម្នាក់ៗ មិនមែនជាការញ៉ុះញ៉ង់ ឬការបង្គាប់ពីសំណាក់កូនក្តីខ្លួន ធម្មតាដីធ្លី ផ្ទះសំបែង ទីលំនៅ គឺជារបស់ពួកគាត់ ចំណុចដែលពួកគាត់បានធ្វើការបញ្ចេញមតិយោបល់គឺជាការទាមទារឲ្យមានដំណោះស្រាយទាំងនោះគឺជាការងារដែលថ្នាក់រដ្ឋបាលអាជ្ញាធរ ដោះស្រាយជាមួយពួកគាត់ ដោយការចរចារជាមួយពួកគាត់ រហូតដល់មានការយល់ព្រម ការសម្របសម្រួលរហូតដល់មានការយល់ព្រម។ ចំពោះការជួបជុំគឺជាប្រពៃណីទំនៀមទម្លាប់របស់ជនជាតិដើមភាគតិចគឺជាចំណុចមួយដែលច្បាប់មិនត្រូវបានហាមឃាត់ទេ ចំពោះការជួបជុំការសែនព្រេនគឺប្រពៃណីជនជាតិដើមភាគតិចដែលពួកគាត់តែងតែធ្វើនៅពេលដែលគាត់ជួនគ្រោះភ័យអាសន្ន ឬខ្លាចឆ្លងជំងឺអ្វីៗផ្សេងៗ ។ចំពោះការអះអាងថាមានយុវជនមកកាប់ឬស្សីរៀបចំក្បូន ទាំងនោះបញ្ជាក់ឲ្យឃើញថាជាសកម្មភាពមួយដែលពួកគាត់ចេះការពារខ្លួនពីគ្រោះទឹកលិចលង់។ចំណុចដែលថារត់គេចទៅភ្នំពេញ គឺមិនពិតទេព្រោះកូនក្តីរបស់ខ្លួនកំពុងរៀនច្បាប់នៅទីក្រុងភ្នំពេញត្រូវជួលផ្ទះនៅទីក្រុងភ្នំពេញហើយម្តាយរបស់គាត់តែងតែទៅមើលថែកូនស្រីជារឿងធម្មតាដូចច្នេះក្នុងនាមខ្លួនជាមេធាវីការពារក្តីឲ្យជនជាប់ចោទស្នើសុំឲ្យកូនក្តីរបស់ខ្លួនរួចពីបទចោទប្រកាន់។

-ជនជាប់ចោទឈ្មោះ [redacted] បាននិយាយសំដីចុងក្រោយថា៖ សុំឲ្យតុលាការឲ្យខ្លួនរួចផុតពីបទចោទប្រកាន់នេះ ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជនជាប់ចោទទាំងបីនាក់

-ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី

-ក្រោយពីបានពិនិត្យភស្តុតាងជាឯកសារក្នុងសំណុំរឿង

**ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ**

**សាលាដំបូងខេត្តស្ទឹងត្រែង**

-យល់ឃើញថា៖ ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ៣៥ឆ្នាំ , [redacted] ភេទស្រី អាយុ៤៨ឆ្នាំ,ឈ្មោះ [redacted] ភេទស្រី អាយុ២៩ឆ្នាំ (មានសវតាជាតិដូចខាងលើ) ត្រូវបានចៅក្រម... ពីបទ៖ ញ៉ុះញ៉ង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋនិងប្រឆាំងអ្នករាជការសាធារណៈប្រព្រឹត្ត

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
ថ្ងៃទី ០៩ ខែ មិនា ឆ្នាំ ២០២១
**ក្រឡាបញ្ជី**
[redacted]

នៅចំណុចទំនប់វារីអគ្គិសនី សេសានក្រោមពីរ ស្ថិតក្នុងភូមិក្បាលរមាស ឃុំក្បាលរមាស ស្រុកសេសានខេត្តស្ទឹងត្រែង កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៧ **តាមបញ្ញត្តិមាត្រា៤៩៥ និងមាត្រា៥០៣ នៃក្រមព្រហ្មទណ្ឌ។**

-យល់ឃើញថាៈ តាមរកំណត់ហេតុស្តីពីបញ្ជូនសំណុំរឿងស៊ើបអង្កេតរបស់ស្នងការដ្ឋាននគរបាលខេត្តស្ទឹងត្រែង ផែនការនគរបាលព្រហ្មទណ្ឌ ការិយាល័យនគរបាលព្រហ្មទណ្ឌកំរិតស្រាល ញុះញ៉ង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ និងប្រឆាំងអ្នករាជការសាធារណៈ នៅភូមិក្បាលរមាសចាស់ ឃុំក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែង កាលពីថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០១៧ រីឯចម្លើយ របស់ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយបដិសេធន៍ថាខ្លួនមិនបានញុះញ៉ង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ និងប្រឆាំងអ្នករាជការសាធារណៈ។ តុលាការយល់ឃើញថាបញ្ជាក់ឲ្យឃើញថាជនជាប់ចោទបានធ្វើបដាហាមឃាត់មិនឲ្យអាជ្ញាធរចូលទៅក្នុងភូមិរបស់ពួកគាត់ព្រមទាំងប្រមូលកម្លាំងពីខេត្តផ្សេងៗ ដែលមាននិន្នាការដូចជាគាត់ចូលទៅក្នុងភូមិក្រោមរូបភាពធ្វើបុណ្យភូមិតាមប្រពៃណី ឃើញថាតាមរកំណត់ហេតុស្តីពីបញ្ជូនសំណុំរឿងស៊ើបអង្កេតរបស់ស្នងការដ្ឋាននគរបាលខេត្តស្ទឹងត្រែង មានលក្ខណៈត្រឹមត្រូវដោយមូលហេតុថា ក្រុមការងារមានឯកសារ ភស្តុតាង និងរបាយការណ៍បញ្ជាក់ច្បាស់លាស់ ចំពោះចម្លើយរបស់ជនជាប់ចោទបានឆ្លើយបដិសេធន៍ គឺគ្រាន់តែជាលេស និងពាក្យដោះសារដែលចង់អោយខ្លួនរួចផុតពីទោសតែប៉ុណ្ណោះ។ ដូចច្នេះតុលាការយល់ឃើញថាជាប់ចោទទាំងបីនាក់គឺពិតជាបាន ញុះញ៉ង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ និងប្រឆាំងអ្នករាជការសាធារណៈប្រាកដមែន។

-យល់ឃើញថាៈ តាមចម្លើយរបស់ជនជាប់ចោទ ឈ្មោះ [redacted] បានឆ្លើយសារភាពថានាថ្ងៃកើតហេតុ ពួកគេបានចូលរួមសែនព្រេនដែលធ្វើឡើងដោយជនជាតិដើមភាគតិចក្នុងគោលបំណងដើម្បីគោរពម្ចាស់ទឹក ម្ចាស់ដីតែប៉ុណ្ណោះ មិនមានចេតនាក្នុងការញុះញង់ និងរារាំងមិនឲ្យសមត្ថកិច្ចចូលទៅក្នុងដីដែនដីនោះឡើយ ហើយពួកខ្លួនបានបញ្ជាក់ថាមិនចាកចេញពីទៅរស់នៅកន្លែងថ្មីឡើយដោយសារតែពួកខ្លួនមានស្រែចំការ និងដំណាំជាច្រើនដែលនៅទីនោះ។ តាមចម្លើយរបស់លោក[redacted] ជាសាក្សីសមត្ថកិច្ចបានបញ្ជាក់ថា ជនជាប់ចោទឈ្មោះ[redacted] និងឈ្មោះ[redacted] គឺជាអ្នកដឹកនាំប្រជាពលរដ្ឋមិនឲ្យធ្វើការដោះដូរទីលំនៅរបស់ពួកគេ ដោយយកមូលហេតុសែនព្រេនតាមប្រពៃណីជនជាតិដើមមកជាសំអាង ដោយលើកឡើងនូវបំរាមថា "អ្នកណាដែលល្មើសនៅក្នុងប្រពៃណីនេះ មានដូចខាងក្រោមនេះ ក្របី១ ក្បាល, ជ្រូក១០០គីឡូ, លុយ១.០០០$ និងស្រា ៧ ពាង"។ យោងទៅតាមចម្លើយរបស់ពួកគេត្រង់អត្ថន័យថា "មិនព្រមចាកចេញពីកន្លែងចាស់ ផ្លាស់ទៅកន្លែងថ្មីដោយមូលហេតុមានស្រែចំការនៅទីនោះ និងមិនព្រមចាកចេញទោះបីទឹកលិចស្លាប់ក៏ដោយ" ត្រង់ន័យនេះគឺបញ្ជាក់ឲ្យឃើញពីធាតុចេតនាក្នុងការរារាំងអ្នករាជការក្នុងការសម្របសម្រួលឲ្យផ្លាស់ទីលំនៅទៅកន្លែងថ្មី និងប្រមូលពលរដ្ឋឲ្យប្រឆាំងទៅនឹងចំណាត់ការរបស់រាជរដ្ឋាភិបាលផងដែរ។ យល់ឃើញថាជនជាប់ចោទឈ្មោះ[redacted] ពិតជាបានចូលរួមក្នុងចលនារារាំងសមត្ថកិច្ច និងញុះញង់ប្រជាពលរដ្ឋមិនឲ្យផ្លាស់លំនៅដ្ឋានទៅកន្លែងថ្មីប្រាកដមែន។ ទង្វើ និងសកម្មភាពរបស់ជនជាប់ចោទទាំងបីរូបខាងលើត្រូវបានច្បាប់កំណត់ជាបទៈញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋនិងប្រឆាំងអ្នករាជការសាធារណៈតាមបញ្ញត្តិមាត្រា៤៩៥ និងមាត្រា៥០៣ នៃក្រមព្រហ្មទណ្ឌ។

[illegible] តាមចម្លើយរបស់សាក្សីឈ្មោះ[redacted] [redacted] បានបញ្ជាក់ថាៈរូបគាត់បានដូរលំនៅ [illegible]អគ្គិសនីសេសានក្រោមពីរ ដោយសារតែរូបគាត់ទទួលបានសំណងគួរជាទីគាប់ចិត្ត ហើយ

[illegible]

[redacted]

រូបគាត់ក៏បានលឺថាសមត្ថកិច្ចចុះឃាត់ខ្លួនឈ្មោះ [redacted] អំពីរឿងតវ៉ាជាមួយសមត្ថកិច្ច។ តាមចម្លើយរបស់សាក្សីបញ្ជាក់ឲ្យឃើញថា ជនជាប់ចោទទាំងបីរូបពិតជាបានចូលរួមក្នុងចលនារារាំងនឹងសមត្ថកិច្ចប្រាកដមែន។

-យល់ឃើញថា: តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] បានបញ្ជាក់ដូចគ្នាថា នាថ្ងៃកើតហេតុពួកគេពិតជាបានចូលរួមប្រារព្ធពិធីសែនព្រៃនតាមទំនៀមទំលាប់របស់ជនជាតិដើមភាគតិច ហើយពួកគេទាំងអស់គ្នាក៏បានលើកឡើងថា ពួកគេមិនព្រមដូរលំនៅដ្ឋានជាដាច់ខាត ដោយពួកគេសុខចិត្តស្លាប់នៅទីនោះ។ យល់ឃើញថា សកម្មភាពសែនព្រៃននេះគឺគ្រាន់តែជាសកម្មភាពបិទបាំងរបស់ឈ្មោះ [redacted] ដែលការពិតពិធីសែនព្រៃននេះ គឺធ្វើឡើងដើម្បីប្រឆាំងទៅនឹងសមត្ថកិច្ចដែលសម្រួលដល់ការដោះដូរទីលំនៅដ្ឋានរបស់ប្រជាពលរដ្ឋប៉ុណ្ណោះ។

-យល់ឃើញថា: តាមចម្លើយសាក្សីឈ្មោះ [redacted] បានបញ្ជាក់ថា: នាថ្ងៃកើតហេតុមានរថយន្តចំនួន ៣គ្រឿង មកពីខេត្តស្ទឹងត្រែង ខេត្តរតនៈគិរី និងខេត្តមណ្ឌលគិរី មកសែនព្រៃន ហើយក៏បានរារាំងទៅលើសបត្ថកិច្ចដោយពលរដ្ឋខ្លះជាក់ទ្វាររថយន្តរបស់សមត្ថកិច្ចដែលកំពុងតែប្រតិបត្តិការលើជូនប្រជាពលរដ្ឋក្នុងការដោះដូរលំនៅដ្ឋាន ដោយលើកឡើងនូវពាក្យថា មិនចាកចេញពីលំនៅដ្ឋានរបស់ពួកគេជាដាច់ខាត។ សកម្មភាពទាំងនេះគឺបញ្ជាក់ឲ្យឃើញថាចលនារារាំងទៅលើអ្នករាជការសាធារណៈពិតប្រាកដមែន។

-យល់ឃើញថា: តាមចម្លើយសាក្សីឈ្មោះ [redacted] បានបញ្ជាក់ថា: ជនជាប់ចោទឈ្មោះ [redacted], ឈ្មោះ [redacted] គឺមេក្រុមក្នុងការប្រឆាំងទៅនឹងអ្នករាជការសាធារណៈ ហើយបានប្រមូលប្រជាពលរដ្ឋមិនឲ្យចាកចេញទៅរស់នៅកន្លែងថ្មីឡើយ។ យល់ឃើញថា ទង្វើ និងសកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ជាបទៈញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋនិងប្រឆាំងអ្នករាជការសាធារណៈតាមបញ្ញត្តិមាត្រា៤៩៥ និងមាត្រា៥០៣ នៃក្រមព្រហ្មទណ្ឌ។

-យល់ឃើញថា: តាមចម្លើយសាក្សីជាសមត្ថកិច្ច សាក្សីជាអភិបាលរងស្រុកសេសាន និងសាក្សីជាមេឃុំក្បាលរមាស បានឆ្លើយបញ្ជាក់ថា ឈ្មោះ [redacted] ពិតជាបានញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋនិងប្រឆាំងអ្នករាជការសាធារណៈដែលប្រព្រឹត្តឡើងដោយជនជាប់ចោទទាំងបីនាក់ពិតប្រាកដមែន។ ទង្វើ និងសកម្មភាពរបស់ជនជាប់ចោទទាំងបីនាក់គឺជាបទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញាត្តិមាត្រា៤៩៥ និងមាត្រា៥០៣ នៃក្រមព្រហ្មទណ្ឌ។

-យល់ឃើញថា: ជបជាប់ចោទឈ្មោះ [redacted] គឺជានីតិជន និងជាជនមានសមត្ថភាពក្នុងការយល់ដឹងគ្រប់គ្រាន់ អាចទទួលខុសត្រូវចំពោះការប្រព្រឹត្តរបស់ខ្លួន។

-យល់ឃើញថា: មានពិរុទ្ធភាព និងភស្តុតាងគ្រប់គ្រាន់សម្រាប់ដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] ពីបទៈ ញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ និងប្រឆាំងអ្នករាជការសាធារណៈ ប្រព្រឹត្តនៅចំណុចទំនប់វារីអគ្គិសនី សេសានក្រោមពីរ ស្ថិតក្នុងភូមិក្បាលរមាស ឃុំក្បាលរមាស ស្រុកសេសានខេត្តស្ទឹងត្រែង កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៧ តាមបញ្ញត្តិមាត្រា៤៩៥ និងមាត្រា៥០៣ នៃក្រមព្រហ្មទណ្ឌ។

**នាងទតចម្លងត្រឹមត្រូវតាមច្បាប់ដើម** ពីដែលជនជាប់ចោទឈ្មោ [redacted]

ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០២១

ក្រឡាបញ្ជី

[redacted]

បានប្រព្រឹត្តធ្វើឱ្យមានផលប៉ះពាល់ដល់សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ និងសន្តិសុខសង្គម ។

-យល់ឃើញថា: តំណាងអយ្យការសុំធ្វើការចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted], ឈ្មោះ [redacted] ពីបទៈ **ញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ និងប្រឆាំងអ្នករាជការសាធារណៈ** ប្រព្រឹត្តនៅចំណុចទំនប់វារីអគ្គិសនី សេសានក្រោមពីរ ស្ថិតក្នុងភូមិក្បាលរមាស ឃុំក្បាលរមាស ស្រុកសេសានខេត្តស្ទឹងត្រែង កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៧ **តាមបញ្ញត្តិមាត្រា៤៩៥ និងមាត្រា ៥០៣ នៃក្រមព្រហ្មទណ្ឌ។**

-យល់ឃើញថា: តាមសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីឲ្យជនជាប់ចោទឈ្មោះ [redacted], ឈ្មោះ [redacted] និងឈ្មោះ [redacted] ស្នើសុំឲ្យតុលាការរួចផុតចោទប្រកាន់ យល់ឃើញថា មិនមានមូលហេតុត្រឹមត្រូវ តុលាការគប្បីមិនលើកយកពិចារណាទេ។

**ហេតុដូច្នេះសម្រេច**

១-ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ៣៥ឆ្នាំ [redacted] ភេទស្រី អាយុ៤៨ឆ្នាំ,ឈ្មោះ [redacted] ភេទស្រី អាយុ២៩ឆ្នាំ (សាវតាជាតិខាងលើ) ដាក់ពន្ធនាគារម្នាក់ៗ កំណត់រយៈពេល ចំនួន១ (មួយ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន **២,០០០,០០០៛ (ពីរ) លានរៀល** គិតចាប់ពីថ្ងៃសាលក្រមចូលជាស្ថាពរ។

ពីបទៈ **ញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ និងប្រឆាំងអ្នករាជការសាធារណៈ** ប្រព្រឹត្តនៅចំណុចទំនប់វារីអគ្គិសនី សេសានក្រោមពីរ ស្ថិតក្នុងភូមិក្បាលរមាស ឃុំក្បាលរមាស ស្រុកសេសានខេត្តស្ទឹងត្រែង កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៧ **តាមបញ្ញត្តិមាត្រា៤៩៥ និងមាត្រា៥០៣ នៃក្រមព្រហ្មទណ្ឌ។**

២-សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ វេលាម៉ោង០៩:០០នាទីព្រឹក និងប្រកាសជាសាធារណៈនៅថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២១ វេលាម៉ោង ៨ :០០នាទីព្រឹក ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] និងឈ្មោះ [redacted]

**ឧកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ៕**

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា

[redacted]

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា

[redacted]

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
ថ្ងៃទី...... ខែ...... ឆ្នាំ២០២១
**ក្រឡាបញ្ជី**

[redacted]